CMAA សមាគមខ្មែរ
CAMBODIAN MUTUAL ASSISTANCE ASSOCIATION OF GREATER LOWELL, INC.

សារពីនាយកប្រតិបត្តិសមាគមខ្មែរ - ខែវិច្ឆិកា ២០២៦

ការដឹងគុណ ភាពរឹងមាំរបស់សហគមន៍ និងការទទួលខុសត្រូវរួមគ្នា

ជូនចំពោះមិត្តភក្តិ ក្រុមគ្រួសារ និងដៃគូសហគមន៍ជាទីគោរព!

ខណៈថ្ងៃបុណ្យនៃសេចក្តីអំណរ (Thanksgiving) ខិតជិតមកដល់ ខ្ញុំបានគិតអំពីការតស៊ូនិងភាពរឹងមាំរបស់សហគមន៍យើងនិងរបៀប ជាច្រើនដែលយើងបន្តជួយមើល ថែគ្នាទៅវិញទៅមក។ នៅឯសមាគមខ្មែរ (CMAA) យើងត្រូវបានក្រើនរំលឹកជារៀងរាល់ថ្ងៃថាសហគមន៍ មិនមែនគ្រាន់តែជាកន្លែងដែលយើងរស់នៅ។ សហគមន៍ក៏ស្ថិត នៅក្នុងទំនាក់ទំនងដែលយើងកសាង ការលំបាកដែលយើងឆ្លងកាត់ជាមួយគ្នា និងការទទួលខុសត្រូវដែលយើងមានរួមគ្នា ដើម្បីឱ្យបងប្អូនក្នុងសហគមន៍មានឱកាសរស់នៅបានល្អប្រសើរ។

ក្នុងខែវិច្ឆិកានេះ ការងាររបស់យើងផ្តោតលើការការពារក្រុមគ្រួសារ ការពង្រឹងភាពជាដៃគូ និងការបង្កើតឱកាសសម្រាប់មនុស្សជំនាន់ក្រោយ។

ដោយសារគោលនយោបាយអន្តោប្រវេសន៍ ស្ថានភាពការពារជាបណ្តោះអាសន្ន (TPS) កម្មវិធីធានារ៉ាប់រងសុខភាព MassHealth និងអត្ថប្រយោជន៍ សាធារណៈផ្សេងៗកំពុងមានការផ្លាស់ប្តូរជាបន្តបន្ទាប់ ក្រុមគ្រួសារជាច្រើនកំពុងប្រឈមនឹងភាពមិនច្បាស់លាស់កាន់តែខ្លាំង។ CMAA បន្តធ្វើការយ៉ាង ជិតស្និទ្ធជាមួយអង្គការក្នុងសហគមន៍និងដៃគូនៅទូទាំងរដ្ឋ ដើម្បីតស៊ូមតិសម្រាប់សហគមន៍យើង និងជួយបុគ្គល ព្រមទាំងគ្រួសារជាច្រើនឱ្យបានយល់និងដោះស្រាយបញ្ហាទាំងនេះ។ ក្នុងស្ថានការណ៍បែបនេះ កន្លែងដែលពួកគេអាច ទុកចិត្តបានដើម្បីសុំការណែនាំ និងសុំជំនួយ មានសារៈសំខាន់ជាងពេលណាៗទាំងអស់។

ទន្ទឹមនឹងនេះ យើងក៏បន្តផ្តោតលើឱកាសដែលនឹងពង្រឹងសហគមន៍របស់យើងទៅថ្ងៃមុខ។ ក្នុងខែនេះ យើងកំពុងស្វែងរកភាពជាដៃគូដើម្បីឱ្យប្រជាជនកាន់តែច្រើន អាចទទួលបានជំនួយផ្នែកច្បាប់ វិធីសន្សំលើថ្លៃទឹកនិងភ្លើង ព្រមទាំងធនធានចាំបាច់ផ្សេងៗ។ យើងក៏កំពុង សហការជាមួយសាកលវិទ្យាល័យ Tufts និងដៃគូផ្នែកវប្បធម៌ក្នុងការជំរុញការបង្រៀនតន្ត្រីប៉ុណ្ណាខ្មែរដើម្បីឱ្យបេតិកភណ្ឌវប្បធម៌របស់ យើងបន្តមានជីវិតសម្រាប់មនុស្សជំនាន់ក្រោយ។

ស្របពេលដែលយើងត្រៀមរៀបចំកិច្ចប្រជុំផែនការរបស់ក្រុមប្រឹក្សាភិបាលសមាគមខ្មែរនៅខែធ្នូខាងមុខ យើងក៏កំពុងគិតអំពីវិធីពង្រឹង ពង្រីកកិច្ចសហការ ជាមួយដៃគូសហគមន៍និងឆ្លើយតបនឹងតម្រូវការដែលកំពុងផ្លាស់ប្តូររបស់សហគមន៍ខ្មែរ និងក្រុមគ្រួសារផ្សេងទៀត ដែលមិនទាន់ទទួលបានសេវាគ្រប់គ្រាន់នៅទូទាំងតំបន់ Greater Lowell។

ខណៈដែលរដូវកាលនៃការធ្វើអំពើសប្បុរសចូលមកដល់ ខ្ញុំសូមអញ្ជើញលោកអ្នកចូលរួមគាំទ្រយុទ្ធនាការអ្នកគ្រាសថវិកាប្រចាំឆ្នាំ ២០២៦ (**Annual Appeal**) របស់ **CMAA** ដើម្បីបន្តផ្តល់សេវាកម្ម និងជួយគាំទ្រដល់កុមារ យុវជន មនុស្សចាស់ និងគ្រួសារនៅក្នុងសហគមន៍របស់យើង។ ខ្ញុំក៏សូមថ្លែងអំណរគុណ យ៉ាងជ្រាលជ្រៅដល់ អ្នកទាំងអស់គ្នាដែលបានចូលរួមក្នុងកម្មវិធីដេញថ្លៃដោយសម្ងាត់ (**Silent Auction**) របស់យើងដែលទើបតែបញ្ចប់ទៅនេះ។ ការចូលរួម ការគាំទ្រ និងអំពើសប្បុរសរបស់លោកអ្នកគឺជាកម្លាំងដ៏សំខាន់ដែលជួយឱ្យយើងបន្តបេសកកម្ម និងពង្រឹងសហគមន៍របស់យើង។

ខ្ញុំសូមឆ្លៀតឱកាសនេះ ថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់បុគ្គលិក ក្រុមប្រឹក្សាភិបាល អ្នកស្ម័គ្រចិត្ត ម្ចាស់ជំនួយ និងដៃគូសហគមន៍របស់យើង។ ការលះបង់ ទឹកចិត្តសប្បុរស និងជំនឿលើបេសកកម្មរបស់យើងពីសំណាក់អ្នកទាំងអស់គ្នា ធ្វើឱ្យការងាររបស់យើងអាចប្រព្រឹត្តទៅបាន។ អ្វីដែលសំខាន់បំផុត ខ្ញុំសូមអរគុណដល់បុគ្គលនិងគ្រួសារជាច្រើនដែលបន្តទុកចិត្តលើ CMAA។

ក្នុងឱកាសបុណ្យនៃសេចក្តីអំណរនេះ សូមយើងចងចាំថា ការដឹងគុណមិនមែនត្រឹមតែការស្ងប់ស្ងែងចំពោះអ្វីដែលកំពុងមានប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងការគិតអំពីអ្វីដែលយើងអាចធ្វើសម្រាប់អ្នកដទៃផងដែរ។

ខ្ញុំបាទនិងក្រុមការងារ CMAA ទាំងមូល សូមជូនពរអ្នកទាំងអស់គ្នានិងមនុស្សជាទីស្រឡាញ់របស់អ្នក ឱ្យមានសុខភាពល្អ និងរីករាយជាមួយទិវានៃក្តីអំណរនេះ។

ដោយការដឹងគុណ

ជៀមរួម សុធា
នាយកប្រតិបត្តិសមាគមខ្មែរ